អង្គភាពសវនកម្មផ្ទៃក្នុង
INTERNAL AUDIT UNIT

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបង្ហាញស្តីពី

# សវតារ និងការកើតការគ្រប់គ្រងអនុលោមភាព

ដោយលោក អ៊ួន រិទ្ធី ប្រធាននាយកដ្ឋានសវនកម្មទី១

ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

@ឯកសារសម្រាប់ប្រើប្រាស់ផ្ទៃក្នុង មិនអាចផ្សព្វផ្សាយជាសាធារណៈ

# មាតិកា


1 សេចក្តីផ្តើម

2 គោលបំណងនៃការរៀបចំឧត្តមានុវត្តន៍

3 ការកើតសវនកម្មផ្ទៃក្នុង

4 ការកើតដំបូងនៃការគ្រប់គ្រងអនុលោមភាព

# ① សេចក្តីផ្តើម

- ដើម្បីឱ្យស្ថាប័នអាចដំណើរការទទួលបានជោគជ័យរយៈពេលវែង មានឆន្ទៈក្នុងការអនុវត្តតាមច្បាប់ ឧត្តមានុវត្តន៍ ក្រមសីលធម៌ និងអភិបាលកិច្ចល្អ
- ស្ថាប័នចាំបាច់ត្រូវមាននូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយដ៏រឹងមាំដែលក្នុងនោះការគ្រប់គ្រងអនុលោមភាពជាផ្នែកមួយដ៏សំខាន់ ក្នុងការជួយស្ថាប័នលើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការទទួលខុសត្រូវលើសកម្មភាពការងាររបស់ខ្លួនឱ្យស្របទៅនឹងច្បាប់ បទប្បញ្ញត្តិ ស្តង់ដា គោលការណ៍ផ្សេងៗពាក់ព័ន្ធដែលមានជាធរមាន។



# ① សេចក្តីផ្តើម (ត)

**ស្ថាប័នដែលគ្រប់គ្រងអនុលោមភាពបានល្អ**

១ ជួយទប់ស្កាត់ និងគ្រប់គ្រងហានិភ័យ

២ កាត់បន្ថយនូវការដាក់បិន្ទុកលើវិន័យទានា

៣ ជួយកសាងកេរ្តិ៍ឈ្មោះរបស់ស្ថាប័ន

៤ បង្កើនទំនុកចិត្តសាធារណជន

# ① សេចក្តីផ្តើម (ត)

➢ ដំណើរការនៃការអនុលោម គឺផ្តើមចេញពីការដឹកនាំក្នុងការអនុវត្តតាមគុណតម្លៃ អភិបាលកិច្ចល្អ និងស្តង់ដាក្រមសីលធម៌

➢ ដូច្នេះដោយមើលឃើញពីសារៈប្រយោជន៍របស់ការគ្រប់គ្រងអនុលោមភាពនេះ មន្ត្រីជំនាញនៃអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** បានរៀបចំឧត្តមានុវត្តន៍នៃការគ្រប់គ្រងអនុលោមភាពនេះឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងពីការគ្រប់គ្រងអនុលោមភាពដល់សវនដ្ឋានអំពីផលប្រយោជន៍នៃអនុលោមភាពដែលជួយស្ថាប័នក្នុងការអភិវឌ្ឍ និងជំរុញនូវឥរិយាបថវិជ្ជមានចំពោះការគ្រប់គ្រងអនុលោមភាពបន្ថែម។





ឧត្តមានុវត្តន៍
នៃការគ្រប់គ្រងអនុលោមភាព



# 2 គោលបំណងនៃការរៀបចំឧត្តមានុវត្តន៍

- ឧត្តមានុវត្តន៍នៃការគ្រប់គ្រងអនុលោមភាពនេះនឹងជួយស្ថាប័នក្នុងការ÷
  - ✓ រៀបចំ ពិនិត្យ វាយតម្លៃលើដំណើរការនៃការអនុវត្តការងារប្រចាំថ្ងៃ
  - ✓ ជួយរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ស្ថាប័នកាន់តែរឹងមាំ និងល្អប្រសើរ
  - ✓ ដើម្បីបញ្ចៀសឬកាត់បន្ថយភាពមិនអនុលោមណាមួយដែលអាចនឹងក្លាយជាកម្មវត្ថុនៃផែនការសវនកម្មអនុលោមភាព។






# 3 ការកកើតសវនកម្មផ្ទៃក្នុង

- កាលពី ៥០០០ ឆ្នាំមុន គ.ស ដំណើរការសវនកម្មផ្ទៃក្នុងត្រូវបានគេសង្កេតឃើញដំបូងតាមរយៈជនជាតិបាប៊ី-ឡូន (Babylonia) ដែលបានប្រើប្រាស់ជីឥដ្ឋ ដើម្បីកត់ត្រា និងត្រួតពិនិត្យលើសកម្មភាពចេញ-ចូលទំនិញ ក្នុងឃ្លាំង។





# 3 ការកកើតសវនកម្មផ្ទៃក្នុង (ត)

- ដំណើរការសវនកម្មផ្ទៃក្នុងត្រូវបានវិវត្តន៍ទៅតាម សម័យកាលផ្សេងៗគ្នានៅឆ្នាំ ១៩៤១ សវនកម្មផ្ទៃក្នុងត្រូវ បានអនុវត្តជាផ្លូវការដោយមានការកត់ត្រា និងពិនិត្យលើ បញ្ជីគណនេយ្យដើម្បីស្វែងរកកំហុស ឬការក្លែងបន្លំ
- ការរីកចម្រើនពិតប្រាកដនៃវិជ្ជាជីវៈសវនកម្មផ្ទៃក្នុងត្រូវ បានកើតឡើងនៅសតវត្សទី១៩ និងទី២០ ជាមួយនឹងការ កកើតឡើងនៃសកម្មភាពអាជីវកម្ម។



## 3 ការកកើតសវនកម្មផ្ទៃក្នុង (ត)

- ឆ្នាំ ១៩៤១ សៀវភៅសវនកម្មផ្ទៃក្នុងដំបូងត្រូវបាននិពន្ធដោយលោក **Victor Z. Brink**
- វិទ្យាស្ថានសវនករផ្ទៃក្នុង ត្រូវបានបង្កើតឡើងដែលបានវិវត្តន៍ និងក្លាយទៅជាមុខងារជំនាញវិជ្ជាជីវៈមួយយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពគ្រប់គ្រងផ្ទៃក្នុងរបស់ស្ថាប័ន។

The Institute of Internal Auditors



# 3 ការកកើតសវនកម្មផ្ទៃក្នុង (ត)

- រហូតមកដល់ឆ្នាំ ២០០៤ សវនកម្មអនុលោមភាពត្រូវបានបង្កើតឡើង ដោយរៀបចំ ផែនការសម្រាប់រៀបចំកិច្ចប្រជុំដំបូងនៅអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល
- ឆ្នាំ ២០០៥ កិច្ចប្រជុំដំបូងអំពីសវនកម្មអនុលោមភាពត្រូវបានរៀបចំឡើងនៅអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល។



# ការកកើតសវនកម្មផ្ទៃក្នុង (ត)

## ការកកើតដំបូងនៃសវនកម្មផ្ទៃក្នុងនៅព្រះរាជាណាចក្រកម្ពុជា

- ច្បាប់ស្ដីពីសវនកម្មផ្ទៃក្នុងត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០០
- អាជ្ញាធរសវនកម្មជាតិ
- អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្ដាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ត្រូវបានប្រកាសឱ្យនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥
- សវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានក្រោមឱវាទរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត។



# 4 ការកើតដំបូងនៃការគ្រប់គ្រងអនុលោមភាព

- គ្រប់សង្គម ឬស្ថាប័នតែងតែមាននូវច្បាប់ និងបទដ្ឋានដែលបង្កើតឡើងសម្រាប់កំណត់ពីសកម្មភាព ដែលត្រូវបានអនុញ្ញាត និងមិនអនុញ្ញាតក្នុងស្ថាប័ន។



# 4 ការកើតដំបូងនៃការគ្រប់គ្រងអនុលោមភាព

- ក្នុងឆ្នាំ ១៩០៦ សហរដ្ឋអាមេរិកបានរៀបចំនូវកម្មវិធីពង្រឹងលើការអនុវត្ត "**អាហារ និងថ្នាំពេទ្យ**" ដើម្បីឆ្លើយតបនឹងការពារសុខុមាលភាពអតិថិជន និងកេរ្តិ៍ឈ្មោះផលិតផល។
- កម្មវិធីអនុលោមភាពដំបូងនេះ រៀបចំដោយផ្តោតសំខាន់ទៅលើ÷
  - ✓ សុវត្ថិភាពសាធារណៈ
  - ✓ និងក្តីកង្វល់សាធារណៈ។



# 4 ការកើតដំបូងនៃការគ្រប់គ្រងអនុលោមភាព

➢ តាមបទពិសោធន៍នៃការអនុវត្តរបស់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ១៩៥០ និងឆ្នាំ១៩៦០ ទស្សនវិទូសង្គមវិទ្យាអាមេរិច បានសិក្សាពីការអនុវត្តអនុលោមភាពទៅនឹងរចនាសម្ព័ន្ធសង្គម (Societal Structures) ហើយចាប់ពីពេលនោះមកមានការទទួលស្គាល់អនុលោមភាព ឬការគ្រប់គ្រងអនុលោមភាពពិតជាមានសារៈសំខាន់សម្រាប់ស្ថាប័ន។



# សូមអរគុណ

# THANKS FOR YOUR ATTENTION



## អង្គភាពសវនកម្មផ្ទៃក្នុង
## INTERNAL AUDIT UNIT





Internal Audit Unit of Non-bank Financial Services Authority
អគារ ១៦៨F ជាន់ទី៩ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ